ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍
លេខ:....៤៧...សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការកែសម្រួលសមាសភាពលេខាធិការដ្ឋាន នៃគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍

### គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញផែនការ លេខ ០៣២ ផ.ក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦ របស់អន្តរក្រសួងមហាផ្ទៃ-ការពារជាតិ ស្តីពីកិច្ចការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ សម្រាប់ដំណើរការរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី ៤
- បានឃើញសេចក្តីសម្រេច លេខ ៥៥ សសរ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការបង្កើតគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី ៤
- បានឃើញសេចក្តីសម្រេច លេខ ០៧ សសរ ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០០៧ ស្តីពីការបង្កើតលេខាធិការដ្ឋាន នៃគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍
- យោងការងារចាំបាច់របស់គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍

### សម្រេច

**ប្រការ ១ :** ត្រូវបានកែសម្រួលសមាសភាពលេខាធិការដ្ឋាន នៃគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ ដូចតទៅ ៖

| | | | | |
|---|---|---|---|---|
| ១- | ឯកឧត្តម នាយឧត្តមសេនីយ៍ | **ហុក ឡុងឌី** | អគ្គស្នងការនគរបាលជាតិ | **ប្រធាន** |
| ២- | ឯកឧត្តម នាយឧត្តមសេនីយ៍ | **មាស សុភា** | អគ្គមេបញ្ជាការរង និងជាមេបញ្ជាការកងទ័ពជើងគោក | **អនុប្រធាន** |

ssd Secretary for Security 2008

| | | | | |
|---|---|---|---|---|
| ៣- | ឯកឧត្តម ឧត្តមសេនីយ៍ឯក | ខៀវ សុភ័គ | អគ្គលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៤- | ឯកឧត្តម ឧត្តមសេនីយ៍ឯក | ជា តារា | នាយរងសេនាធិការចម្រុះ និងជានាយកទីចាត់ការកលយុទ្ធ | សមាជិក |
| ៥- | ឯកឧត្តម ឧត្តមសេនីយ៍ឯក | ជា សារិន | នាយសេនាធិការកងទ័ពជើងគោក | សមាជិក |
| ៦- | ឯកឧត្តម ឧត្តមសេនីយ៍ឯក | នេត សាវឿន | អគ្គស្នងការរងនគរបាលជាតិ | សមាជិក |
| ៧- | ឯកឧត្តម ឧត្តមសេនីយ៍ឯក | យូ ស៊ីនឡុង | អគ្គស្នងការរងនគរបាលជាតិ | សមាជិក |
| ៨- | ឯកឧត្តម ឧត្តមសេនីយ៍ឯក | ម៉ៅ ចន្ទតារា | អគ្គស្នងការរងនគរបាលជាតិ | សមាជិក |
| ៩- | ឯកឧត្តម ឧត្តមសេនីយ៍ឯក | សុខ ផល | អគ្គស្នងការរងនគរបាលជាតិ | សមាជិក |
| ១០- | ឯកឧត្តម ឧត្តមសេនីយ៍ឯក | ស៊ឹម សុផល | អគ្គស្នងការរងនគរបាលជាតិ និងជាប្រធាននាយកដ្ឋានកណ្តាលនគរបាលព្រំដែន | សមាជិក |
| ១១- | ឯកឧត្តម ឧត្តមសេនីយ៍ឯក | ឯម សំណាង | អគ្គនាយករង នៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ | សមាជិក |
| ១២- | ឯកឧត្តម ឧត្តមសេនីយ៍ឯក | គន្ធ សំអឿន | ប្រធាននាយកដ្ឋានកណ្តាលសន្តិសុខ | សមាជិក |
| ១៣- | ឯកឧត្តម ឧត្តមសេនីយ៍ឯក | យុន ឈុន្នី | ប្រធាននាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈ | សមាជិក |
| ១៤- | ឯកឧត្តម ឧត្តមសេនិយ៍ឯក | ទ៊ាន់ ណរាយ | ប្រធាននាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ | សមាជិក |
| ១៥- | លោក ឧត្តមសេនីយ៍ទោ | គង់ មុន្នី | មេបញ្ជាការរងកងទ័ពអាកាស | សមាជិក |
| ១៦- | លោក ឧត្តមនាវីទោ | មាស ថខ | មេបញ្ជាការរងកងទ័ពជើងទឹក | សមាជិក |
| ១៧- | លោក ឧត្តមសេនីយ៍ទោ | អៅ គឹមឈួន | ប្រធាននាយកដ្ឋានកណ្តាលមធ្យោបាយ | សមាជិក |
| ១៨- | លោក ឧត្តមសេនីយ៍ទោ | គៀត ចន្ទថារិទ្ធ | ប្រធានសេនាធិការដ្ឋាន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ | សមាជិក |
| ១៩- | លោក ឧត្តមសេនីយ៍ទោ | ឆៃ ស៊ីណារិទ្ធ | ប្រធាននាយកដ្ឋានព័ត៌មានទូទៅ | សមាជិក |
| ២០- | លោក ឧត្តមសេនីយ៍ទោ | ម៉ិក ជីតូ | ប្រធាននាយកដ្ឋាននគរបាលព្រហ្មទណ្ឌ | សមាជិក |
| ២១- | លោក ឧត្តមសេនីយ៍ទោ | ទ៊ាន់ រដ្ឋា | ប្រធាននាយកដ្ឋាននគរបាលបច្ចេកទេសវិទ្យាសាស្ត្រ | សមាជិក |
| ២២- | លោក ឧត្តមសេនីយ៍ត្រី | តួច ស៊ីតិន | នាយរងសេនាធិការកងរាជអាវុធហត្ថ | សមាជិក |

Secretary for Security 2008

២៣- លោក ឧត្តមសេនីយ៍ត្រី **នៅ សុខិណា** ប្រធាននាយកដ្ឋានប្រឆាំងភេរវកម្ម **សមាជិក**

២៤- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ **សមាជិក**

**ប្រការ ២ :** លេខាធិការដ្ឋាន នៃគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ មានភារកិច្ច ដូចតទៅ ៖

- ជួយប្រធានគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ ក្នុងការផ្សព្វផ្សាយ តាមដាន និងចាត់តាំងអនុវត្តផែនការលេខ ០៣២ ផ.ក ចុះថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់អន្តរក្រសួងមហាផ្ទៃ-ការពារជាតិ ស្តីពីកិច្ចការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ សម្រាប់ដំណើរការរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី ៤ ឆ្នាំ ២០០៨ ។
- ផ្សព្វផ្សាយផែនការ បទបញ្ជា និងសេចក្តីណែនាំផ្សេងៗ របស់គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ ទៅគណៈបញ្ជាការឯកភាពគ្រប់លំដាប់ថ្នាក់ ។
- ចាត់តាំងកម្លាំង ដើម្បីប្រតិបត្តិការការពារការបោះឆ្នោត តាមផែនការដែលបានកំណត់ ។
- ប្រមូលផ្តុំពត៌មានពីគណៈបញ្ជាការឯកភាពគ្រប់លំដាប់ថ្នាក់ ដើម្បីរាយការណ៍ជូនប្រធានគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ ។
- ពិនិត្យដោះស្រាយរាល់វិវាទផ្សេងៗ ឬបណ្តឹងតវ៉ាពាក់ព័ន្ធដល់សន្តិសុខសម្រាប់ការបោះឆ្នោត ធ្វើរបាយការណ៍ ជូនគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ រៀងរាល់ ១៥ ថ្ងៃម្តង ។
- រៀបចំកិច្ចប្រជុំ និងធ្វើលិខិតអញ្ជើញគ្រប់សមាជិក នៃគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ទាំងអស់ តាមការសម្រេចរបស់ប្រធានគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ ។
- ធ្វើគម្រោងថវិកា ឧបករណ៍ សម្ភារៈ មធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទ សម្រាប់បម្រើការងារបោះឆ្នោត ដាក់ជូនប្រធានគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ពិនិត្យសម្រេច ។
- ប្រមូលផ្តុំ ចាត់ចែង ប្រើប្រាស់សម្ភារៈ ឧបករណ៍ និងមធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទរបស់បណ្តាអង្គភាពផ្ទាល់ដែលមានស្រាប់ ដើម្បីបម្រើប្រតិបត្តិការរក្សាសន្តិសុខ សណ្តាប់ធ្នាប់ឱ្យបានល្អប្រសើរ ក្នុងរយៈពេលនៃដំណើរការរៀបចំការបោះឆ្នោត ។
- ចាត់ចែងផ្តល់ថវិកាបំប៉នជូនកម្លាំងការពារតាមគោលដៅ និងធ្វើគម្រោងបែងចែកនូវឧបករណ៍សម្ភារៈ និងមធ្យោបាយផ្សេងៗ ឱ្យបានសមស្របទៅតាមមុខសញ្ញា និងគោលដៅចាំបាច់ ។
- ធ្វើរបាយការណ៍ចំណូល ចំណាយថវិកា និងប្រើប្រាស់ឧបករណ៍ សម្ភារៈ និងមធ្យោបាយគ្រប់ប្រភេទប្រចាំខែ ជូនគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ ដើម្បីរាយការណ៍ជូនរាជរដ្ឋាភិបាល ។
- ផ្សព្វផ្សាយនៅក្នុង និងទៅក្រៅប្រទេស នូវពត៌មានទាំងឡាយណាដែលពិនិត្យឃើញថា ចាំបាច់ត្រូវជូនដល់សាធារណមតិជាតិ និងអន្តរជាតិ បានជ្រាប ។

**ប្រការ ៣ :** ក្នុងករណីចាំបាច់ លេខាធិការដ្ឋានអាចស្នើសុំទៅគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ ដើម្បីបង្កើតក្រុមការងារជាជំនួយការ ក្នុងការតាមដាន ដឹកនាំបញ្ជា និងកិច្ចការរដ្ឋបាល ។ លេខាធិការដ្ឋាន នៃគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងមហាផ្ទៃ ។

**ប្រការ ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ អគ្គស្នងការនគរបាលជាតិ និងសមាសភាព ដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ សីហា ឆ្នាំ ២០០៧*

**ប្រធានគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍**

ស ខេង

**អន្លែងទទួល :**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី ស ខេង
-ក្រសួងមហាផ្ទៃ
-ក្រសួងការពារជាតិ
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-អគ្គលេខាធិការដ្ឋាន គ.ជ.ប
-លេខាធិការដ្ឋាន គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍
-អគ្គស្នងការដ្ឋាននគរបាលជាតិ
-អគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ
-បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស
-គ្រប់គណៈបញ្ជាការឯកភាពខេត្ត ក្រុង
-ដូចប្រការ ១
-ឯកសារ កាលប្បវត្តិ